

# រឿងសម្ងាត់របស់ព្រះរាជា

Kuzhali Manickavel

Emanuele Scanziani

Let's Read

The Asia Foundation

ស្របពេលដែលអ្នកនិពន្ធ ជាងគំនូរ និងអ្នកបោះពុម្ពសៀវភៅ
នេះលើកទឹកចិត្ត និងគាំទ្រការបកប្រែសៀវភៅនេះជាភាសា
ផ្សេងៗក៏ដោយ ពួកគេក៏សំណូមពរសូមអោយការកែប្រែផ្នែកសំ
ខាន់ៗនៃអត្ថបទស្ថិតក្នុងកម្រិតអប្បបរមាប៉ុណ្ណោះ។



កាលពីព្រេងនាយមានស្តេចមួយអង្គមានបុត្រាមួយអង្គដែល
មានព្រះកាណ៌គោ។



ព្រះរាជាមានសេចក្តីអៀនខ្មាសដោយសារព្រះរាជបុត្រ ហើយ
លាក់ទ្រង់ទុកនៅក្នុងបន្ទប់ដាច់ពីគេមួយនៅក្នុងរាជវាំង។



មិនយូរប៉ុន្មាន វេលានៃពិធីកោរព្រះកេសាក៏បានមកដល់។ ព្រះរាជាបានហៅជាងកាត់សក់ប្រចាំរាជវាំងពីនគរផ្សេងមក ហើយពិធីនោះត្រូវបានធ្វើឡើងជាសម្ងាត់។



ក្រោយបញ្ចប់ពិធី ព្រះរាជាបានកោះហៅជាងកាត់សក់នោះ ទៅដំណាក់ផ្ទាល់ខ្លួនរបស់ព្រះអង្គ ហើយគំរាមគាត់ថា« មិនត្រូវប្រាប់អ្នកណាម្នាក់ពីព្រះកាណ៌របស់ព្រះរាជបុត្រឡើយ។ បើសិនជាឯងហ៊ាននោះ យើងនឹងបោះឯងចូលទៅក្នុងគុកងងឹត!»។



ជាងកាត់កេសាបានសន្យាមិននិយាយពីរឿងនេះប្រាប់នរណាម្នាក់ឡើយ។ ប៉ុន្តែព្រះអើយ បុរសជាជាងកាត់កេសានោះជាមនុស្សមាត់ដាច។ ប៉ុន្មានថ្ងៃក្រោយមក ពោះរបស់គាត់ក៏ចាប់ផ្តើមប៉ោងធំឡើងៗ។ ជាងកាត់កេសាបានគិតថា «ខ្ញុំត្រូវតែប្រាប់អ្នកណាម្នាក់ពីការសម្ងាត់នេះ បើ មិនអញ្ចឹងទេពោះរបស់ខ្ញុំនឹងបែកជាមិនខានឡើយ»



ស្រាប់តែពេលនោះ គាត់បានគិតឃើញគំនិតដ៏អស្ចារ្យមួយ។ គាត់ក៏បានដើរទៅកាន់ដើមឈើចំណាស់មួយដើមហើយខ្សឹបប្រាប់ដើមឈើនោះពីការសម្ងាត់នោះភ្លាម។ រំពេចនោះ ពោះរបស់គាត់ក៏ស្រកទៅដូចដើមវិញ ហើយគាត់ក៏មានអារម្មណ៍ធូរស្រាល។ ជាងកាត់កេសានោះគិតថា «ដើមឈើមួយដើមនេះពិតជាអាចរក្សាការសម្ងាត់នេះបានជាក់ជាមិនខាន»។



ប៉ុន្មានថ្ងៃក្រោយមក មានបុរសជាអ្នកវាយស្គរម្នាក់បានដើរឆ្លងកាត់ទីនោះ ដើម្បីស្វែងរកឈើល្អៗយកមកធ្វើស្គរថ្មី។ គាត់ក៏បានមកឈប់ចំពីមុខដើមឈើដែលជាងកាត់កេសាបានខ្សឹបប្រាប់ពីការសម្ងាត់នោះ។



«ពិតជាអ្វីដែលខ្ញុំកំពុងរកមែន!» គាត់បានគិតក្នុងចិត្ត ដោយ
សម្លឹងមើលទៅកាន់ដើមឈើនោះ។



មិនយូរប៉ុន្មាន គាត់ក៏ធ្វើបានស្គរថ្មីមួយ ហើយបានធ្វើដំណើរ
ទៅកាន់រាជវាំងដើម្បីច្រៀងថ្វាយព្រះរាជា។



អ្នកយាមទ្វាររីករាយជាខ្លាំងនៅពេលបានឃើញបុរសនោះមកដល់។ «ចូរអ្នកច្រៀងចម្រៀងណាដែលធ្វើអោយព្រះរាជាសប្បាយចិត្ត» អ្នកយាមទ្វារបាននិយាយទៅកាន់បុរសនោះ។ «ថ្ងៃនេះទ្រង់មិនសប្បាយក្នុងព្រះទ័យទេ»។



ភ្លាមៗនោះ ស្គរបានចាប់ផ្ដើមច្រៀងដោយខ្លួនឯង។ «ខ្ញុំមានការសម្ងាត់មួយដែលគ្មាននរណាម្នាក់គួរដឹងឡើយ។ ព្រះបុត្រារបស់ព្រះរាជាមានព្រះកាណ៌គោ!»



អ្នកយាមទ្វារក៏ស្ទុះមកទាញយកស្គរនោះ ហើយថែមទាំងស្រែកដាក់បុរសវាយស្គរផងដែរ។ អ្នកយាមទ្វារបាននិយាយថា «គ្មាននរណាម្នាក់អាចទម្លាយអាថ៌កំបាំងរបស់ព្រះរាជាបានទេ» ។ «ឆាប់រត់ចេញឲ្យឆ្ងាយទៅ មុនពេលដែលមានគេចាប់អ្នក!» ប៉ុន្តែវាយឺតពេលទៅហើយ។



ព្រះរាជាបានឮចម្រៀងនោះរួចទៅហើយ ហើយទ្រង់ក៏បានបញ្ជាអោយអ្នកយាមនាំយកបុរសវាយស្គរនោះចូលគាល់។



បុរសវាយស្គរដ៏កំសត់ត្រូវបានគេអូសចូលទៅក្នុងទីជំនុំជម្រះ។ «ចូរបោះបុរសនេះចូលទៅក្នុងគុកក្រោមដីទៅ!» ព្រះរាជាបានស្រែកទាំងកំហឹងឡើង។ ចំណែកអ្នកយាមទ្វារក៏បានទូលថា «ប៉ុន្តែតាមពិតគាត់មិនមែនជាអ្នកច្រៀងទេ។ ស្គររបស់គាត់ទេតើដែលជាអ្នកច្រៀងនោះ ក្រាបទូល»។



«បើអីចឹង ចូរបោះស្គរនោះចូលទៅក្នុងគុកក្រោមដីដែរទៅ» ព្រះរាជាស្រែកបញ្ជា។ «ហើយចូរដាក់ទោសអ្នកទាំងនោះ ដែលបានព្នកាសម្ងាត់របស់យើងផង!» ព្រះអង្គខ្ញាល់ខ្លាំងណាស់ រហូតពុកមាត់របស់ទ្រង់ឡើងញ័រ។



អ្នកយាមបានឈានជើងទៅមុខយ៉ាងក្លាហាន ហើយទូល
ថា « ក្រាបទូលព្រះអង្គ បើអីចឹងមែននោះ ព្រះអង្គគួរតែបោះ
ប្រជារាស្ត្ររបស់ព្រះអង្គមួយនគរចូលទៅក្នុងគុកក្រោមដីផង
ដែរទៅ ក្រាបទូល ត្បិតអីពួកយើងសុទ្ធតែដឹងពីការសម្ងាត់របស់
ព្រះអង្គគ្រប់គ្នា»។



ព្រះរាជាភ្ញាក់ផ្អើលជាខ្លាំង។ គាត់សម្លឹងទៅកាន់មន្ត្រីដែលគាត់ទុកចិត្តបំផុត ហើយសួរថា «តើរឿងនេះពិតមែនដែរទេ?»។ លោកមន្ត្រីបានឆ្លើយតបថា «ក្រាបទូល ព្រះអង្គ នេះជាការពិត»។ «ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា មិនហ៊ាននិយាយអ្វីទេ ព្រោះយើងមិនចង់អោយព្រះអង្គមិនសប្បាយព្រះទ័យ»។



ព្រះរាជាមានក្ដីអាម៉ាស់ជាខ្លាំង។ ទ្រង់ក៏ដឹងខ្លួនថាទ្រង់ពិតជា
បិតាដ៏ឃោរឃៅមែន ដែលបានបង្ខាំងបុត្រាខ្លួនទុកជាច្រើនឆ្នាំ។



ទ្រង់ក៏បានរៀបចំក្បួនដង្ហែដ៏ពិសេសមួយ ហើយនាំព្រះបុត្រាទស្សនាជុំវិញព្រះនគរ។ ប្រជារាស្ត្របានអបអរសាទរ និងគ្រវីដៃទៅកាន់ព្រះរាជបុត្រា បើទោះបីជាព្រះអង្គមានព្រះកាណ៌ដូចសត្វគោក៏ដោយ។



នៅថ្ងៃបន្ទាប់ ព្រះរាជាបានប្រកាសឲ្យមានថ្ងៃសម្រាកមួយ។ អ្នកយាមទ្វារបានដឹកនាំក្បួនដង្ហែដោយមានបុរសជាអ្នកវាយស្គរនៅបន្ទាប់ វាយស្គរថ្មីរបស់គាត់ហែហមជាមួយផងដែរ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The King's Secret*, Author: Kuzhali Manickavel. Illustrator: Emanuele Scanziani. Published by BookBox, © BookBox. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Wanna Net and Solyda Say